# មេរៀនទី៥១៖ ជនជាតិអ៊ីស្រាអែលឆ្លងទន្លេយ័រដាន់

## យ៉ូស្វេ ៣៖១-៤៖២៤

**មេរៀន** ( *យូធូបលីង* )៖ https://youtu.be/pogJJujSc8w

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/ByDVZygPG04

**គោលបំណង៖** ថ្វាយការអរព្រះគុណដល់ព្រះជាម្ចាស់ដោយដឹងថា ព្រះដ៏មានព្រះជន្មរស់គង់នៅជាមួយយើង

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ៩៖១** *"ទូលបង្គំនឹងសរសើរដល់ព្រះយេហូវ៉ាអស់អំពីចិត្តទូល បង្គំនឹងនិទានពីអស់ទាំងការអស្ចារ្យរបស់ទ្រង់"។*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះជាម្ចាស់ កូនសូមអរគុណព្រះអង្គ https://youtu.be/UT6rpTYplU0
២. អរគុណ អរគុណព្រះអង្គ នៅក្នុងចិត្ត https://youtu.be/MdYoscjxNeo
៣. អរព្រះគុណ https://youtu.be/g0QKUUZJ-LE

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត « ការអរព្រះគុណ »

១. ឲ្យកុមារទាំងអស់ក្រោកឈរ ហើយនិយាយពីអ្វីដែលគេចង់អរគុណដល់ព្រះ។ ពួកគេមិនអាចនិយាយអ្វីដែលដូចនឹងអ្វីដែលកុមារផ្សេងទៀតបាននិយាយរួចហើយនោះទេ។
២. រំលឹកកុមារថាមានវិធីជាច្រើនដែលយើងអាចបង្ហាញពីការអរគុណរបស់យើងទៅកាន់ព្រះអម្ចាស់។

### ៤. ការណែនាំមេរៀន

សូមចាំថាអ្វីដែលយើងបានរៀនពីប៉ុន្មានសប្តាហ៍មុន ព្រះបានដឹកនាំជនជាតិអ៊ីស្រាអែលទៅកាន់ទឹកដីសន្យា។ ព្រះអង្គបានការពារពួកគេនៅតាមផ្លូវ ហើយប្រទាននូវអ្វីដែលពួកគេត្រូវការ។ ព្រះក៏បានធ្វើបែបនេះសំរាប់យើងដែរ។ ប៉ុន្តែទោះបីជាយើងដឹងថា ព្រះតែងតែជួយដល់យើងក៏ដោយ តែយើងក៏មិនត្រូវភេងចំណេញពីការជួយរបស់ទ្រង់នោះឡើយ។ យើងត្រូវចងចាំពីការជួយរបស់ព្រះ ហើយអរព្រះគុណទ្រង់សំរាប់ការជួយទាំងអស់នោះ។ ព្រះតែងតែឆ្លើយតបនឹងការអធិស្ឋានរបស់យើង។ ទ្រង់នឹងជួយហើយដឹកនាំយើងរាល់ថ្ងៃ។ សូមចាំថា យើងត្រូវបែរទៅរកព្រះអង្គ ហើយអរគុណទ្រង់ ចំពោះអ្វីៗដ៏អស្ចារ្យដែលទ្រង់បានធ្វើសំរាប់យើង។

### ៥. រឿងនៅក្នុងព្រះគម្ពីរ

ពេលជនជាតិអ៊ីស្រាអែលបានទៅដល់ទឹកដីដែលព្រះបានសន្យា ទើបពួកគេដឹងថាពួកគេមានបញ្ហា។ នៅកំឡុងពេលដែលពួកគេកំពុងធ្វើដំណើរ រហូតដល់ពេលដែលពួកគេទៅដល់មាត់ច្រាំងទន្លេយ័រដាន់។ ពួកគេបានដឹងហើយថា ពួកគេមានបញ្ហាហើយ ដោយពួកគេត្រូវដើរឆ្លងទន្លេយ័រដាន់ទៅកាន់ទឹកដីសន្យា។

ទឹកទន្លេយ័រដាន់គឺហូរលឿនណាស់ ហើយធំល្វឹងល្វើយ និងជ្រៅទៀតផង។ ការពិតទៅពេលនោះ វាមើលទៅដូចទឹកប្រៀបប្រាំងទៅហើយ។

យ៉ូស្វេ និងអ្នកដឹកនាំជនជាតិអ៊ីស្រាអែលដទៃទៀត បានប្រាប់ជនជាតិអ៊ីស្រាអែលឲ្យត្រៀមខ្លួនដើម្បីព្រះជាម្ចាស់ទ្រង់ធ្វើការអស្ចារ្យ។ ពួកគេបាននិយាយថា ព្រះគម្ពីរយ៉ូស្វេ ៣៖ "***គឺដោយហិបនៃសេចក្តីសញ្ញាផងព្រះអម្ចាស់នៃផែនដីទាំងមូល នឹងនាំមុខឯងរាល់គ្នាទៅក្នុងទន្លេយ័រដាន់***"។ ដូច្នេះ ពេលដែលពួកសង្ឃចាប់ផ្តើម សែងហិបនៃសេចក្តីសញ្ញាផងព្រះអម្ចាស់សំដៅទៅទន្លេយ័រដាន់ ជនជាតិអ៊ីស្រាអែលក៏បានដើរទៅតាម។ ពេលដែលពួកសង្ឃបានដាក់ជើងចុះ១៣ទៅក្នុងទឹកទន្លេ ពិតជាមានការអស្ចារ្យបានកើតឡើងមែន! ទឹកទន្លេឈប់ហូរ ហើយទឹកក៏ឈប់នៅនឹងឡើងជាគំនរនៅមួយកន្លែង! ពួកសង្ឃជាអ្នកដែលបានសែងហិបនៃសេចក្តីសញ្ញាគេក៏បានឈរនឹងនៅដីស្ងួតនាបាតទន្លេ ហើយជនជាតិអ៊ីស្រាអែលទាំងអស់គ្នាក៏ឆ្លងទន្លេយ័រដាន់លើដីស្ងួត!

បន្ទាប់ពីជនជាតិអ៊ីស្រាអែលបានឆ្លងកាត់ទន្លេយ័រដាន់រួច យ៉ូស្វេបានប្រាប់ពួកគេឲ្យប្រមូលយកដុំថ្ម ១២ ដុំពីកណ្តាលទន្លេ។ បន្ទាប់មកពួកសង្ឃបានសែងហិបនៃសេចក្តីសញ្ញាដើរចេញពីទន្លេ ហើយទន្លេយ័រដាន់ក៏ចាប់ផ្តើមហូរធម្មតាម្តងទៀត។ ជនជាតិអ៊ីស្រាអែលបានយកថ្មទាំងនោះ ទៅកាន់ត្រើយម្ខាងទៀតនៃទន្លេ ហើយបានសង់ជាគំនរថ្មយ៉ាងធំ។ ថ្មទាំងអស់នេះនឹងរំលឹកពួកគេពីឆ្នាំនៃការ អរព្រះគុណព្រះ ចំពោះអ្វីដែលព្រះបានធ្វើសំរាប់ពួកគេ។ យ៉ូស្វេបានប្រាប់ជនជាតិអ៊ីស្រាអែលថា **យ៉ូស្វេ ៤៖២១-២៤ "កាលណាដល់ថ្ងៃក្រោយ កូនចៅឯងរាល់គ្នាសួរឪពុកថា តើថ្មទាំងនេះមានន័យដូចម្តេច នោះត្រូវ ប្រាប់ឲ្យដឹងថា គឺពួកអ៊ីស្រាអែល យើងបានឆ្លងទន្លេយ័រដាន់នេះនៅដីស្ងួត ពីព្រោះព្រះយេហូវ៉ា ជាព្រះនៃយើងទ្រង់បានធ្វើឲ្យទឹកទន្លេយ័រដាន់ រីងទៅនៅមុខយើងទាល់តែបានឆ្លងផុតមក.....ទ្រង់ធ្វើបែបនេះគឺដើម្បីឲ្យគ្រប់ទាំងសាសន៍នៅផែនដីបានដឹងថា ព្រះហស្តនៃព្រះយេហូវ៉ាមានព្រះចេស្តា ប្រយោជន៍ឲ្យឯងរាល់គ្នាបានកោតខ្លាចដល់ព្រះយេហូវ៉ាជាព្រះនៃឯងជាដរាបតទៅ"**។ ដូចដែលជនជាតិអ៊ីស្រាអែលបានធ្វើ យើងក៏ត្រូវការរំលឹកពីខ្លួនយើងថា ត្រូវតែអរព្រះគុណព្រះអង្គជានិច្ចសំរាប់គ្រប់យ៉ាង ដែលព្រះបានធ្វើសំរាប់យើង។

## ៦. សំនួរពិភាក្សា

១. តើបញ្ហាអ្វីខ្លះដែលជនជាតិអ៊ីស្រាអែលបានជួបនៅពេលដែលពួកគេព្យាយាមចូលទៅទឹកដីសន្យា? (*ពួកគេត្រូវឆ្លងទន្លេយ័រដាន់*)

២. តើអ្នកណាជាអ្នកដើរចូលទៅក្នុងទន្លេយ័រដាន់មុនគេបង្អស់? *(ពួកសង្ឃជាមួយនឹងហិបនៃសេចក្តីសញ្ញា)*

៣. តើមានអ្វីបានកើតឡើងនៅពេលដែលពួកសង្ឃបានដើរចូលទៅក្នុងទន្លេ? ( *ទឹកទន្លេឈប់ហូរ*)

៤. តើជនជាតិអ៊ីស្រាអែលបានសាងសង់អ្វីសំរាប់ជាការរំលឹកដល់កូនចៅដើម្បីជាការអរព្រះគុណព្រះ? (*ពួកគេបានសង់គំនរថ្មធំមួយដែលយកចេញពីកណ្តាលនៃទន្លេយ័រដាន់*)

៥. តើប្អូនអាចប្រើអ្វីបានខ្លះ ដើម្បីរំលឹកពីការអរព្រះគុណដល់ព្រះ?

(**អាចនឹងមិនលែងល្បែងទៀតដូច្នេះកុមារនឹងអាចធ្វើកាត "អរគុណអ្នក" បានច្រើន**)

## ៧. ខគម្ពីរចងចាំ

**ទំនុកដំកើង ៩៖១** «ទូលបង្គំនឹងសរសើរដល់ព្រះយេហូវ៉ាអស់អំពីចិត្តទូលបង្គំនឹងនិទានពីអស់ ទាំងការអស្ចារ្យរបស់ទ្រង់ »។

**៨. ហាត្ថកម្ម** « កាតអរគុណអ្នក »

១. បោះពុម្ពគម្រូកាត ៉ អរគុណអ្នក ៉សំរាប់ចែកឲ្យកុមារ ( សូមមើលទំព័រខាងក្រោម )

២. ពួកគេអាចតុបតែងកាត/ផាត់ពណ៌ ហើយសរសេរពីការអរគុណចំពោះនរណាម្នាក់ដែលពួកគេចង់ថ្លែងអំណរគុណ។

៣. ការថ្លែងអំណរគុណចំពោះមនុស្សដែលនៅជុំវិញយើង ធ្វើឲ្យព្រអង្គសប្បាយព្រះទ័យ។ បើសិនជាកុមារធ្វើហើយលឿនអាចឲ្យគេធ្វើកាតថ្មីមួយទៀត។

**១០. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**១០. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូះ ( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន )**
សូមអានគម្ពីរ **យ៉ូស្វេ ៤៖២៤** ម្តងទៀត។ កត់សំគាល់ការបង្ហាញជាសាធារណៈពីអំណាចដែលព្រះបានទុកឲ្យដូចជាការរំលឹកពីក្តីស្រឡាញ់ និងអំណាចរបស់ទ្រង់។ នៅក្នុងពេលវេលាដ៏លំបាក វាតែងតែជួយយើងឲ្យចាំពីអ្វីដែលយើងមានបទពិសោធន៍ពីអតីតកាល។ ជួបជាមួយព្រះសង្គ្រោះយើង រំលឹកយើងថាទ្រង់គង់នៅជាមួយយើង។ ការចែកចាយពីបទពិសោធន៍របស់យើងជាមួយអ្នកដទៃអាច ផ្តល់ក្តីសង្ឃឹមដល់អ្នកដែលបាត់បង់ក្តីសង្ឃឹម ហើយនាំសិរីល្អសំរាប់ការងារដែលព្រះបានធ្វើ នៅក្នុងយើង។ សូមកំណត់អត្តសញ្ញាណមនុស្ស៥នាក់ ជាមនុស្សដែលអ្នកនឹងថ្លែងពីបន្ទាល់នៃអំណាចរបស់ ព្រះនៅក្នុងជីវិតអ្នកក្នុងសប្តាហ៍នេះ។ បន្ទាប់ពីអ្នកចែកចាយរួចហើយ សូមរងចាំមើលថាអំណាច របស់ព្រះដែលមាននៅក្នុងជីវិតអ្នកបានប៉ះពាល់ដល់មនុស្សដែលអ្នកបានចែកចាយដោយរបៀបណា ?

# កាត “អរគុណអ្នក”



